Strategic Planning Committee
International School of Phnom Penh
88 Hun Neang Boulevard, P.O. Box 138, Phnom Penh, Cambodia

AGM April 29, 2020

# របាយការណ៍ជូនចំពោះកិច្ចប្រជុំទូទៅប្រចាំឆ្នាំ
# ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០

## ការបង្កើតគណៈកម្មាធិការ និងសមាជិកភាព

គណៈកម្មាធិការផែនការ និងយុទ្ធសាស្ត្រ (SPC) បណ្តោះអាសន្ន ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំសិក្សា ២០១៨-២០១៩ ដោយក្នុងពេលនេះគណៈកម្មាធិការ បានអនុវត្តសកម្មភាពត្រៀមរៀបចំ ដើម្បីឱ្យដំណើរការធ្វើផែនការសំខាន់ៗអាចចាប់ផ្តើមបានឆាប់រហ័ស នៅក្នុងឆ្នាំសិក្សានេះ។ សមាជិកភាពរបស់ SPC រួមមានដូចខាងក្រោម៖ John Collins និង Peter Herum តំណាងឱ្យក្រុមប្រឹក្សាភិបាល Murray Polglase តំណាងឱ្យបុគ្គលិកសិក្សាថ្នាក់មធ្យមសិក្សា Tom Parun តំណាងឱ្យបុគ្គលិកសិក្សាថ្នាក់បឋមសិក្សា Lindy Leonhardt តំណាងឱ្យក្រុមការងារផ្នែករដ្ឋបាលសាលា និង Scott Johnson តំណាងឱ្យ PCO។ Gareth Jones ដែលជានាយកសាលា បានធ្វើជាសហអ្នកដឹកនាំដំណើរការធ្វើផែនការយុទ្ធសាស្ត្រ រួមជាមួយ Jenny Pearson ដែលជាសមាជិកក្រុមប្រឹក្សាភិបាល និងជាប្រធាន SPC។

## សកម្មភាព

មានការសម្រេចចិត្តថា រចនាសម្ព័ន្ធរបស់ផែនការ គួរផ្តោតលើសសរស្តម្ភចម្បងចំនួនបី រួមមាន៖ ការរៀនសូត្រ, សហគមន៍, និងបរិស្ថាន និងសុខុមាលភាព ព្រមទាំងសសរស្តម្ភបន្ទាប់បន្សំចំនួនបីគឺ៖ អភិបាលកិច្ច និងភាពជាអ្នកដឹកនាំ, កេរ្តិ៍ឈ្មោះ, និងហិរញ្ញវត្ថុ បរិក្ខារ និងធនធាន។ អនុគណៈកម្មាធិការ ត្រូវបានបង្កើតឡើង សម្រាប់សសរស្តម្ភនីមួយៗ ដោយមានសមាជិក SPC ជាប្រធាន ហើយរួមមានសមាសភាពសមាជិកជាអ្នកស្ម័គ្រចិត្ត មកពីបុគ្គលិកសិក្សា ប្រតិបត្តិការបុគ្គលិក និងឪពុកម្តាយ។ ភារកិច្ចរបស់អនុគណៈកម្មាធិការទាំងនេះ គឺដើម្បីធ្វើការវិភាគបរិបទជាយុទ្ធសាស្ត្រ លើបញ្ហាពាក់ព័ន្ធនានា សម្រាប់សសរស្តម្ភរបស់ខ្លួន កំណត់រកមូលន័យយុទ្ធសាស្ត្រសម្រាប់សាលាក្នុងរយៈពេលប្រាំឆ្នាំខាងមុខ និងផ្តល់អនុសាសន៍សម្រាប់គោលដៅ និងគោល

បំណងដែលត្រូវសម្រេចឱ្យបាន។ បន្ទាប់ពី សិក្ខាសាលាណែនាំដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំបូកសរុបរបស់ក្រុមប្រឹក្សាភិបាលក្នុងខែវិច្ឆិកា អនុគណៈកម្មាធិការនីមួយៗ បានធ្វើការជួបប្រជុំចន្លោះពីបួនលើក ដល់ប្រាំពីរលើក រហូតដល់ខែកុម្ភៈ។ Gareth និង Jenny បានចូលរួមក្នុងកិច្ចប្រជុំអនុគណៈកម្មាធិការជាច្រើន តាមដែលអាចធ្វើបាន ដើម្បីធានាឱ្យមានការសម្របសម្រួល លើបញ្ហាជាច្រើនដែលជាបញ្ហាអន្តរវិស័យ សម្រាប់សសរស្តម្ភលើសពីមួយ។ SPC ក៏បានជួបប្រជុំក្នុងឱកាសជាច្រើន ក្នុងអំឡុងពេលនេះផងដែរ ដើម្បីធានាបានថា ដំណើរការទាំងមូលត្រូវបានសម្របសម្រួល និងដើរតាមគន្លងត្រឹមត្រូវ។

កាលពីដំបូង មានផែនការធ្វើសិក្ខាសាលារយៈមួយថ្ងៃ ដើម្បីឱ្យក្រុមប្រឹក្សាភិបាលទាំងមូល និង SPC មករួមគ្នា ដើម្បីពិចារណាលើរាល់អនុសាសន៍ទាំងអស់ និងធ្វើការសម្រេចចិត្តអំពីអ្វីដែលត្រូវអនុម័ត ដាក់ឱ្យមានក្នុងផែនការ។ ប៉ុន្តែអាស្រ័យដោយការបិទសាលារៀន កិច្ចពិគ្រោះយោបល់ត្រូវបានធ្វើឡើង តាមអនឡាញជំនួសវិញ។

ឯសារដែលមានបង្ហាញជូននៅក្នុង AGM គឺជាលទ្ធផលបានមកពីការច្របាច់បញ្ចូលគ្នានៃសកម្មភាពទាំងអស់ ដូចមានបញ្ជាក់ខាងលើ។ បន្ទាប់ពីការអនុម័តពីសំណាក់ក្រុមប្រឹក្សាភិបាល ក្រុមការងាររដ្ឋបាលសាលា នឹងចាប់ផ្តើមដំណើរការក្នុងការធ្វើផែនការលម្អិត និងរៀបចំថវិកាសម្រាប់ការអនុវត្តក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។

Jenny Pearson<br>
សមាជិកក្រុមប្រឹក្សាភិបាល និងប្រធាន SPC<br>
ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២០